# ការត្រួតពិនិត្យ និងវាយតំលៃ

ដោយ ទ្បេង ឆាយ

## ១. និយមន័យ

### ការត្រួតពិនិត្យ (Monitoring)

ការត្រួតពិនិត្យគឺជា ការសង្កេត ឆ្លុះបញ្ចាំង និងកែតំរូវ ជាបន្ត បន្ទាប់ទៅលើសកម្មភាពអនុវត្តគំរោង។ ការត្រួតពិនិត្យ មានគោលបំណង កែតំរូវផែនការ និងសកម្មភានានា ឈានទៅបង្កើនគុណភាពនៃការអនុវត្តគំរោង។

### ការវាយតំលៃ (Evaluation)

ការវាយតំលៃជាការប៉ាន់ប្រមាណនៅពេលណាមួយ ដើម្បីវិនិច្ឆ័យថា តើគំរោងបានសំរេចគោលបំណងរបស់ខ្លួនដែរឬទេ ហើយ មានឥទ្ធិពលអ្វីខ្លះ ដែលកើតឡើងដោយសារគំរោង? គោលបំណងនៃការវាយតំលៃគឺប៉ាន់ប្រមាណនិងវាស់វែងឥទ្ធិពលនានារបស់គំរោង ចំពោះក្រុមគោលដៅ ដើម្បីធ្វើការសំរេចចិត្តលើការរៀបចនិងអនុវត្តគំរោង សំរាប់ដំណាក់កាលបន្ទាប់ (អនាគត)។

## ២. តើយើងត្រូវត្រួតពិនិត្យ និងវាយតំលៃទៅលើផ្នែកណាខ្លះ?

| ការអភិវឌ្ឍអង្គការ | គំរោង/កម្មវិធី |
|---|---|
| • ទិសដៅអង្គការ ផែនការវែង និងខ្លី<br>• រចនាសម្ព័ន្ធ ប្រព័ន្ធការងារ<br>• គោលនយោបាយនានា<br>• សមត្ថភាពបុគ្គលិក<br>• ទំនាក់ទំនងបុគ្គលិក គុណតំលៃ ។ល។ | • ផលសំរេចបាន<br>• ឥទ្ធិពល (មធ្យម និងវែង)<br>• ជោគជ័យ និងការប្រឈមនានា<br>• កត្តាជួយគាំទ្រ និងកត្តារារាំង<br>• ប្រសិទ្ធភាព និងប្រសិទ្ធផល ។ល។ |

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

## ៣. ឧបករណ៍មួយចំនួន សំរាប់ការត្រួតពិនិត្យ និងវាយតំលៃ

| ឧបករណ៍ TOOLS | |
|---|---|
| **1.** សូចនាករ | Indicators |
| **2.** តារាង/បញ្ជីកត់ត្រា ឬស្ថិតិ | Track record/ statistics |
| **3.** បញ្ជី/សំនួរត្រួតពិនិត្យ | Monitoring check-list/ questionnaires |
| **4.** វដ្តរៀនសូត្រពីសកម្មភាព | Action-learning Cycle |
| **5.** ទំរង់វាយតំលៃបុគ្គលិក | Staff Appraisal Form |
| **6.** កិច្ចប្រជុំត្រួតពិនិត្យពាក់កណ្តាលឆ្នាំ | Mid-year Review Meeting |
| **7.** សំរង់ពាក្យសំដី | Quotes |
| **8.** បញ្ជីសំនួរផ្លូវការ | Questionnaires |
| **9.** បញ្ជីសំនួរពាក់កណ្តាលផ្លូវការ | Semi-structured Questions |
| **10.** រឿងរ៉ាវផ្លាស់ប្តូរ | Stories of Change |
| **11.** លក្ខខណ្ឌយោង | Terms of Reference (TOR) |
| **12.** របាយការណ៍ (រួមទាំងទំរង់) | Reports (including formats) |

## ៤. អ្វីទៅជា ប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃ?

វាជាគ្រោងការមួយ ដែលបំរើអោយសកម្មភាពត្រួតពិនិត្យ និងវាយតំលៃរបស់អង្គការមួយ។ វាបញ្ជាក់ពីខ្លឹមសារនៃចំនុចសំខាន់ៗ (ដូចជា សូចនាករ ឧបករណ៍...) រួមទាំងការណែនាំសំរាប់អង្គការមួយធ្វើការត្រួតពិនិត្យ និងវាយតំលៃ។ ខ្លឹមសារសំខាន់ៗរួមមាន:

- ចំណងជើង (ឈ្មោះអង្គការ និងប្រព័ន្ធ)
- និយមន័យត្រួតពិនិត្យ និងវាយតំលៃសំរាប់អង្គការ
- គោលបំណងនៃការត្រួតពិនិត្យ និងវាយតំលៃ
- ប្រភេទ និងនិយមន័យសូចនាករសំរាប់បរិបទអង្គការ
- ផែនការត្រួតពិនិត្យ និងវាយតំលៃ
- ឧបសម្ព័ន្ធ (ឧបករណ៍ និងទំរង់របាយការណ៍)

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

# អ្វីទៅជាសូចនាករ (Indicators)?

វាជាឧបករណ៍ ឬស្តង់ដា ជាមូលដ្ឋាន សំរាប់វាស់វែងជោគជ័យ ឬផលសំរេចរបស់គំរោង។ សូចនាករកំនត់ លទ្ធផលការងារ (ជាចំនួន និងឥទ្ធិពល) ដែលរំពឹងទុកថានឹងធ្វើអោយសំរេចដោយគំរោង។

មានសូចនាករសំខាន់ៗ ៤ ប្រភេទ:

## សូ. ឥទ្ធិពល រយៈពេលវែង
## Impact Indicators

ការប្រែប្រួល លក្ខខណ្ឌ ឬស្ថានភាព របស់ក្រុមគោលដៅ សហគមន៍ ឬសង្គមទាំងមូល។ ឧទាហរណ៍:

- អ្នកភូមិ៩០%មានស្បៀងអាហារបរិភោគពេញមួយឆ្នាំ។
- អំពើហិង្សាក្នុងសហគមន៍ថយចុះ ៥០%។

## សូ. ឥទ្ធិពល រយៈពេលមធ្យម
## Outcomes Indicators

ការប្រែប្រួល អាកប្បកិរិយា ផ្នត់គំនិត ទំលាប់ ទស្សនៈ: ទំនាក់ទំនង សកម្មភាព និងលទ្ធផលអនុវត្តការងារ របស់ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធ។ ឧទាហរណ៍:

- ក្រុមគោលដៅមានមុខរបរយ៉ាងតិច ៣ បន្ថែមលើមុខរបរចាស់
- ស្ត្រីយ៉ាងតិច ៦០% ដែលបានចូលរួម មានភាពក្លាហាន។ បុរស ៥០% ប្តូរអាកប្បកិរិយា ឈប់វាយដំភរិយា ឈប់ផឹកសុរា...

## សូ. ទិន្នផល
## Outputs Indicators

លទ្ធផលភ្លាមៗ ចេញពីសកម្មភាព ឬដំណើរការរបស់គំរោង។ វាជាផលិតផល សេវា ឬចំនេះដឹង ដែលគំរោងនឹងបង្កើតឡើង។

ឧទាហរណ៍:

- អ្នកភូមិ ៣០០នាក់បានចូលរួមវគ្គបណ្តុះបណ្តាលកសិកម្ម និង អាជីវកម្មខ្នាតតូច ក្នុងនោះ ៨០%បានយល់ច្បាស់។
- ស្ត្រី ៥០នាក់ទទួលបានការប្រឹក្សាយោបល់។ បុរស ៥០នាក់បាន ចូលរួមក្នុងវគ្គ បុរសមិនប្រើហិង្សា ក្នុងនោះ ៨០%យល់ច្បាស់។

## សូ. ធនធាន
## Inputs Indicators

ជាធនធាន: សំភារ: បរិក្ខា មធ្យោបាយ មនុស្ស ថវិកា ដែលបាន ប្រើប្រាស់សំរាប់ផលិតចេញជាទិន្នផល។

ឧទាហរណ៍:

- បុគ្គលិកបំរើការងារចំនួន២នាក់
- ម៉ូតូ ១ ។ សំភារ:សំរាប់បង្រៀន ១ឈុត។

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.